**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤១១៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ២២... ខែកញ្ញា... ឆ្នាំ ២០១៦...

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** ៖ របាយការណ៍ប្រចាំសប្តាហ៍ស្តីពីសភាពការណ៍នៃល្បឿនការងារបង្កបង្កើនផលដំណាំរដូវវស្សាឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍នៃល្បឿនការងារបង្កបង្កើនផលដំណាំរដូវវស្សាឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ មានដូចតទៅ ÷

## I. **ល្បឿនការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

### **១- ការងារដាំដុះ ÷**

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ២ ៩២០ ១៥៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៥៣ ៨២៨ហ.ត (ស្មើនឹង៨,៦៩%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៦៦៦ ៣២៧ហ.ត (ស្មើនឹង៩១,៣១%) តិចជាងឆ្នាំមុន ៥០៦ ៧០៩ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៣៦៦ហ.ត តិចជាងឆ្នាំមុន ១៩ ៤៥៩ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥១៨ ៨៧៤ហ.ត ស្មើនឹង១០១,៧១%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៧២ ១១៩ហ.តស្មើនឹង៦,៤០% និងស្រូវតាមប្រភេទមាន÷

- ស្រូវស្រាលចំនួន ៦០៧ ៥៣៦ ហ.ត (ក្នុងនោះស្រូវបង្កើនរដូវចំនួន ១៥៣ ៦៧៨ហ.ត) លើសឆ្នាំមុន ៦៤ ៨០៥ហ.ត
- ស្រូវកណ្តាលចំនួន ១ ២៨១ ៦៦៧ហ.ត លើសឆ្នាំមុន ២៣ ១៤៣ហ.ត
- ស្រូវធ្ងន់ចំនួន ៥៦០ ៧៧៥ហ.ត លើសឆ្នាំមុន ១ ៧៦៧ហ.ត
- ស្រូវចម្ការចំនួន ២៨ ១៦៧ហ.ត តិចជាងឆ្នាំមុន ១១ ៥៥២ហ.ត
- ស្រូវឡើងទឹកចំនួន ៤០ ៧២៩ហ.ត តិចជាងឆ្នាំមុន ៦ ០៤៤ហ.ត។

### **២- ល្បឿនការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

ការងារប្រមូលផលស្រូវស្រាលដើមរដូវរហូតមកដល់ពេលនេះ សម្រេចបានចំនួន ១៩០ ២៧២ហ.ត លើផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៦០៧ ៥៣៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧៦៧ ១៤៩តោន លើសមុនឆ្នាំ ២៣៦ ៩២៤តោន។ ទិន្នផលគិតជាមធ្យម **៤,០៣២តោន/ហ.ត** លើសឆ្នាំមុន ៤០១ គ.ក្រ/ហ.ត។

## II. **ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

ក - ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៨១៧ ៣៥០ហ.ត ស្មើនឹង ១៣២,៦៦% នៃផែនការ ៦១៦ ១២៣ហ.ត លើសឆ្នាំមុន ៨៣ ១៩៣ ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ៨៣ ០៩២ហ.ត ស្មើនឹង ៦០,៥៥% នៃផែនការ ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុន ២៨ ១៩៧ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## III - ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ

គ្រោះខ្វះទឹកប៉ះពាល់លើផ្ទៃដីសរុបចំនួន ១៣២ ៨៧៧ហ.ត ក្នុងនោះមានសំណាបសរុបចំនួន ៦៦៨ហ.ត និងសន្ទូង-ពង្រោះសរុបចំនួន ១៣២ ២០៩ហ.តក្នុងនោះខូចខាតលើសន្ទូង-ពង្រោះសរុបចំនួន ១១ ៣៤៩ហ.ត។ ខេត្តដែលទទួលរងនូវការប៉ះពាល់និងខូចខាតមានដូចខាងក្រោម÷

| ល.រ | រាជធានី-ខេត្ត | ប៉ះពាល់ (ហាត) | | ប៉ះពាល់ (ហាត) សប្តាហ៍មុន | | ខូចខាត (ហាត) | | ខូចខាត (ហាត) សប្តាហ៍មុន | |
|---|---|---|---|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| ១ | បន្ទាយមានជ័យ | - | 12 894 | - | 2160 | - | - | - | - |
| ២ | បាត់ដំបង | - | 63 308 | - | 63 308 | - | 11 349 | - | 3 992 |
| ៣ | កំពង់ស្ពឺ | 601 | 2 818 | 601 | 2 818 | - | - | - | - |
| ៤ | សៀមរាប | - | 1 249 | - | 1 249 | - | - | - | - |
| ៥ | តាកែវ | - | 14897 | - | 11 734 | - | - | - | - |
| ៦ | ពោធិ៍សាត់ | - | 11 462 | - | 11 462 | - | - | - | - |
| ៧ | កំពង់ឆ្នាំង | 67 | 109 | 67 | 109 | - | - | - | - |
| ៨ | កណ្តាល | - | 1 617 | - | 1 617 | - | - | - | - |
| ៩ | ស្វាយរៀង | - | 23 416 | - | 23 416 | - | - | - | - |
| ១០ | ប៉ៃលិន | - | 57 | - | 57 | - | - | - | - |
| ១១ | កំពង់ចាម | - | 292 | - | 292 | - | - | - | - |
| ១២ | កំពត | - | 90 | - | 90 | - | - | - | - |
| សរុប | | 668 | 132 209 | 668 | 118 312 | - | 11 349 | - | 3 992 |

## IV. សេចក្តីសន្និដ្ឋាន

រហូតមកដល់សប្តាហ៍ទី០៣ នៃខែកញ្ញានេះ ដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសសម្រេចបាន ១០១,៧១% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត។ ខេត្តចំនួន ១១ ត្រូវបានបញ្ចប់ការងារដាំដុះដំណាំស្រូវរដូវវស្សាហើយ (សប្តាហ៍មុនមាន ១០ខេត្ត)។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយក្នុងកម្រិតមធ្យមទៅបង្គួរនៅទូទាំងប្រទេស ហើយនៅតាមតំបន់ខ្លះក៏ពុំទាន់មានទឹកដក់គ្រប់គ្រាន់នៅឡើយដែរ។ តាមការកត់សម្គាល់ឃើញថា ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំនេះ ប្រជាកសិករធ្វើស្រូវព្រោះច្រើនជាងស្ទូងគឺស្មើនឹង៨៨,៩២%។ ម៉្យាងទៀតនៅតាមតំបន់ខ្លះដំណាំស្រូវរបស់ប្រជាកសិករបានទទួលនូវផលប៉ះពាល់ដោយខ្វះទឹក។ ជាមួយនឹងការបន្តជំរុញការងារបង្កបង្កើនផលដំណាំរដូវវស្សា ក៏ដូចជាការធ្វើកសិកម្មចម្រុះយ៉ាងសកម្មរួមផ្សំផងនោះ ក្រសួងបានណែនាំដល់អង្គភាពជំនាញក្រោមឱវាទ មន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ ឱ្យចុះពិនិត្យតាមដានអំពីបញ្ហាទាំងឡាយ ដែលកើតមាននៅលើដំណាំស្រូវ ក៏ដូចជាដំណាំកសិកម្មផ្សេងៗទៀត រួមទាំងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធក្នុងការអន្តរាគមន៍បូមទឹកបញ្ចូលស្រែនៅតំបន់ដែលមានប្រភពទឹក ដើម្បីទប់ស្កាត់ការបាត់បង់ទិន្នផលជាយថាហេតុ។ ជាពិសេសការចូលរួមទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវ នៅតាមបណ្តាខេត្តមួយចំនួនដើម្បីស្វែងរកដំណោះស្រាយទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រសួងកំពុងចាត់ចែងជាបន្តក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ព្រមទាំងការចាត់មន្ត្រីជំនាញដើម្បីត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូលឱ្យបានសមស្របតាមវិធានបច្ចេកទេស និងនីតិវិធីដោយអនុលោមតាមស្មារតីនៃលិខិតលេខ៩៤២ សជណ.កស ចុះថ្ងៃ០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  “**ដើម្បីជូនជ្រាប**”
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  “**ដើម្បីជ្រាប**”
- ឯកសារ កាលប្បវត្តិ

## ក្រាហ្វិក


ប្រៀបធៀបល្បឿនការងារបង្កបង្កើនផលស្រូវក្នុងរយៈពេលដូចគ្នា
ផ្ទៃដីដាំដុះបាន(ហិកតា)
2,600,000
2,400,000
2,200,000
2,000,000
1,800,000
2,352,629
2,123,629
2,420,317
2,226,786
2,463,466
2,291,139
2,497,018
2,373,082
2,518,874
2,446,755
សប្តាហ៍ទី៤ នៃសីហា
សប្តាហ៍ទី៥ នៃសីហា
សប្តាហ៍ទី១ នៃកញ្ញា
សប្តាហ៍ទី២ នៃកញ្ញា
សប្តាហ៍ទី៣ នៃកញ្ញា
ឆ្នាំ២០១៦
ឆ្នាំ២០១៥


ប្រៀបធៀបផ្ទៃដីដាំដុះស្រូវរដូវវស្សាសម្រេចបានតាមខែ ពីឆ្នាំ២០១០-២០១៦
ផ្ទៃដីដាំដុះបាន(ពាន់ហិកតា)
3000
2500
2000
1500
1000
500
0
2010
2011
2012
2013
2014
2015
2016
ឧសភា
មិថុនា
កក្កដា
សីហា
កញ្ញា
តុលា


ប្រៀបធៀបផ្ទៃដីដាំដុះស្រូវរដូវវស្សាសម្រេចបានតាមខែ ពីឆ្នាំ២០១០-២០១៦
ផ្ទៃដីដាំដុះបាន(ពាន់ហិកតា)
3000
2500
2000
1500
1000
500
0
ឧសភា
មិថុនា
កក្កដា
សីហា
កញ្ញា
តុលា
2013
2014
2015
2016

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនប្រមូលផលស្រូវស្រាលដើមរដូវវស្សា ឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | | ផ្ទៃដីប្រមូលផល | ទិន្នផល | បរិមាណផល | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រូវស្រាល | (ហត) | (តោន/ហ.ត) | (តោន) | (%) | |
| 01 | បន្ទាយមានជ័យ | 247,015 | 53,235 | 34,030 | 4.532 | 154,209 | 63.92 | 19-09-2016 |
| 02 | បាត់ដំបង | 288,056 | 73,957 | 20,304 | 4.341 | 88,139 | 27.45 | 19-09-2016 |
| 03 | កំពង់ចាម | 85,563 | 23,013 | 4,746 | 3.653 | 17,336 | 20.62 | 16-09-2016 |
| 04 | កំពង់ឆ្នាំង | 121,788 | 6,003 | 1,663 | 3.235 | 5,379 | 27.70 | 19-09-2016 |
| 05 | កំពង់ស្ពឺ | 91,584 | 11,113 | 653 | 3.352 | 2,189 | 5.88 | 07-09-2016 |
| 06 | កំពង់ធំ | 215,526 | 31,300 | 12,045 | 4.033 | 48,575 | 38.48 | 20-09-2016 |
| 07 | កំពត | 121,856 | 22,161 | | | | - | |
| 08 | កណ្ដាល | 31,201 | 9,652 | 8,520 | 3.756 | 32,002 | 88.27 | 13-09-2016 |
| 09 | កោះកុង | 10,503 | 2,237 | | | | - | |
| 10 | ក្រចេះ | 33,072 | 13,091 | 861 | 2.561 | 2,205 | 6.58 | 02-08-2016 |
| 11 | មណ្ឌលគិរី | 23,608 | 3,392 | 235 | 2.889 | 679 | 6.93 | 07-09-2016 |
| 12 | ភ្នំពេញ | 10,007 | 4,232 | 82 | 2.976 | 244 | 1.94 | 13-09-2016 |
| 13 | ព្រះវិហារ | 82,398 | 13,499 | | | | - | |
| 14 | ព្រៃវែង | 256,404 | 54,580 | 39,063 | 3.757 | 146,779 | 71.57 | 16-09-2016 |
| 15 | ពោធិ៍សាត់ | 115,412 | 49,146 | 2,483 | 3.123 | 7,754 | 5.05 | 19-09-2016 |
| 16 | រតនគិរី | 24,011 | 2,967 | | | | | |
| 17 | សៀមរាប | 186,735 | 39,700 | | | | - | |
| 18 | ព្រះសីហនុ | 16,605 | 1,500 | | | | - | |
| 19 | ស្ទឹងត្រែង | 28,678 | 10,697 | | | | | |
| 20 | ស្វាយរៀង | 167,802 | 58,391 | 13,560 | 3.860 | 52,341 | 23.22 | 20-09-2016 |
| 21 | តាកែវ | 187,028 | 88,022 | 48,956 | 4.076 | 199,529 | 55.62 | 20-09-2016 |
| 22 | ឧត្ដរមានជ័យ | 86,501 | 20,119 | | | | - | |
| 23 | កែប | 3,466 | 978 | 254 | 3.539 | 899 | 25.97 | 07-09-2016 |
| 24 | ប៉ៃលិន | 5,825 | 1,660 | | | | | |
| 25 | ត្បូងឃ្មុំ | 78,230 | 12,891 | 2,817 | 3.156 | 8,890 | 21.85 | 16-09-2016 |
| សរុប | | **2,518,874** | **607,536** | **190,272** | **4.032** | **767,149** | **31.32** | |
| តួលេខសប្ដាហ៍មុន | | **2,497,018** | **600,650** | **154,743** | **3.924** | **607,250** | **25.76** | |
| តួលេខឆ្នាំ២០១៥ | | **2,446,755** | **542,731** | **146,029** | **3.631** | **530,225** | **26.91** | |
| ប្រៀបធៀបឆ្នាំមុន | | **72,119** | **64,805** | **44,243** | **0.401** | **236,924** | **4.41** | |

បានឃើញនិងឯកភាព
ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦

(គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផែនការ | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហ.ត) | | | | | | សរុបស្ទូង និងព្រោះបុកដាំ (ហ.ត) | ភាគរយ (%) | ថ្ងៃខែឆ្នាំ រាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចម្ការ | ឡើងទឹក | | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | | |
| 01 | បន្ទាយមានជ័យ | 245,000 | 249,667 | - | - | 249,667 | 100.00 | 2 | 53,235 | 39,177 | 138,772 | 44,362 | - | 10,646 | 247,015 | 100.82 | បញ្ចប់ |
| 02 | បាត់ដំបង | 269,800 | 288,427 | 111 | 0.04 | 288,316 | 99.96 | 416 | 73,957 | 29,248 | 120,312 | 88,297 | 486 | 5,004 | 288,056 | 106.77 | 19-09-2016 |
| 03 | កំពង់ចាម | 86,540 | 88,057 | 13,301 | 15.10 | 74,756 | 84.90 | 478 | 23,013 | 5,346 | 35,959 | 25,541 | - | 1,050 | 85,563 | 98.87 | 16-09-2016 |
| 04 | កំពង់ឆ្នាំង | 121,800 | 218,979 | 47,587 | 21.73 | 171,392 | 78.27 | 9,677 | 6,003 | 918 | 90,268 | 25,202 | - | 315 | 121,788 | 99.99 | 19-09-2016 |
| 05 | កំពង់ស្ពឺ | 113,600 | 165,891 | 46,485 | 28.02 | 119,406 | 71.98 | 7,548 | 11,113 | 653 | 54,412 | 25,966 | 93 | - | 91,584 | 80.62 | 19-09-2016 |
| 06 | កំពង់ធំ | 213,300 | 217,963 | 17,530 | 8.04 | 200,433 | 91.96 | 1,674 | 31,300 | 6,998 | 101,998 | 69,542 | 2,166 | 10,520 | 215,526 | 101.04 | បញ្ចប់ |
| 07 | កំពត | 126,000 | 125,629 | 21,796 | 17.35 | 103,833 | 82.65 | 8,960 | 22,161 | - | 52,204 | 47,483 | 8 | - | 121,856 | 96.71 | 19-09-2016 |
| 08 | កណ្តាល | 39,340 | 43,587 | 6,297 | 14.45 | 37,290 | 85.55 | 666 | 9,652 | 4,335 | 12,231 | 9,080 | 190 | 48 | 31,201 | 79.31 | 16-09-2016 |
| 09 | កោះកុង | 10,476 | 9,600 | 1,989 | 20.72 | 7,611 | 79.28 | 610 | 2,237 | - | 6,079 | 971 | 1,216 | - | 10,503 | 100.26 | បញ្ចប់ |
| 10 | ក្រចេះ | 33,000 | 33,235 | 4,893 | 14.72 | 28,342 | 85.28 | 2,993 | 13,091 | 861 | 17,076 | 2,728 | 177 | - | 33,072 | 100.22 | បញ្ចប់ |
| 11 | មណ្ឌលគិរី | 23,000 | 26,658 | 142 | 0.53 | 26,516 | 99.47 | 2,591 | 3,392 | - | 14,471 | 3,293 | 2,452 | - | 23,608 | 102.64 | បញ្ចប់ |
| 12 | ភ្នំពេញ | 11,120 | 10,097 | 3,299 | 32.67 | 6,798 | 67.33 | 445 | 4,232 | - | 4,857 | 918 | - | - | 10,007 | 89.99 | 13-09-2016 |
| 13 | ព្រះវិហារ | 80,870 | 81,340 | 4,562 | 5.61 | 76,778 | 94.39 | 3,212 | 13,499 | - | 45,059 | 21,028 | 2,812 | - | 82,398 | 101.89 | បញ្ចប់ |
| 14 | ព្រៃវែង | 250,000 | 256,404 | 4,692 | 1.83 | 251,712 | 98.17 | 118 | 54,580 | - | 149,722 | 52,102 | - | - | 256,404 | 102.56 | 20-09-2016 |
| 15 | ពោធិ៍សាត់ | 100,000 | 129,885 | 1,032 | 0.79 | 128,853 | 99.21 | 1,570 | 49,146 | 326 | 38,750 | 20,944 | 821 | 5,751 | 115,412 | 115.41 | 19-09-2016 |
| 16 | រតនគិរី | 26,200 | 14,457 | 2,830 | 19.58 | 11,627 | 80.42 | 1,652 | 2,967 | - | 6,904 | 4,586 | 9,554 | - | 24,011 | 91.65 | បញ្ចប់ |
| 17 | សៀមរាប | 186,200 | 212,870 | 21,730 | 10.21 | 191,140 | 89.79 | 2,985 | 39,700 | - | 93,790 | 42,015 | 3,835 | 7,395 | 186,735 | 100.29 | បញ្ចប់ |
| 18 | ព្រះសីហនុ | 16,600 | 16,600 | 4,150 | 25.00 | 12,450 | 75.00 | 69 | 1,500 | - | 10,905 | 4,200 | - | - | 16,605 | 100.03 | 07-09-2016 |
| 19 | ស្ទឹងត្រែង | 27,800 | 25,926 | 3,517 | 13.57 | 22,409 | 86.43 | 2,379 | 10,697 | - | 14,030 | 1,169 | 2,782 | - | 28,678 | 103.16 | បញ្ចប់ |
| 20 | ស្វាយរៀង | 167,000 | 167,953 | 12,338 | 7.35 | 155,615 | 92.65 | 234 | 58,391 | 13,567 | 100,581 | 8,830 | - | - | 167,802 | 100.48 | 20-09-2016 |
| 21 | តាកែវ | 170,000 | 351,645 | 34,550 | 9.83 | 317,095 | 90.17 | 1,580 | 88,022 | 48,956 | 91,635 | 7,371 | - | - | 187,028 | 110.02 | 20-09-2016 |
| 22 | ឧត្តរមានជ័យ | 72,000 | 97,699 | - | - | 97,699 | 100.00 | 64 | 20,119 | - | 44,724 | 20,083 | 1,575 | - | 86,501 | 120.14 | បញ្ចប់ |
| 23 | កែប | 3,500 | 3,491 | 697 | 19.97 | 2,794 | 80.03 | 260 | 978 | 476 | 1,685 | 803 | - | - | 3,466 | 99.03 | 20-09-2016 |
| 24 | ប៉ៃលិន | 5,000 | 5,825 | - | - | 5,825 | 100.00 | 1 | 1,660 | - | 4,039 | 126 | - | - | 5,825 | 116.50 | បញ្ចប់ |
| 25 | ត្បូងឃ្មុំ | 78,300 | 78,270 | 300 | 0.38 | 77,970 | 99.62 | 182 | 12,891 | 2,817 | 31,204 | 34,135 | - | - | 78,230 | 99.91 | 16-09-2016 |
| សរុប | | 2,476,446 | 2,920,155 | 253,828 | 8.69 | 2,666,327 | 91.31 | 50,366 | 607,536 | 153,678 | 1,281,667 | 560,775 | 28,167 | 40,729 | 2,518,874 | 101.71 | |
| តួលេខសប្តាហ៍មុន | | 2,476,446 | 2,881,570 | 249,712 | 8.67 | 2,631,858 | 91.33 | 50,364 | 600,650 | 153,622 | 1,268,673 | 558,353 | 28,167 | 40,675 | 2,496,518 | 100.81 | |
| តួលេខឆ្នាំមុន | | 2,567,130 | 3,426,864 | 406,606 | 11.87 | 3,020,258 | 88.13 | 69,825 | 542,731 | 135,301 | 1,258,524 | 559,008 | 39,719 | 46,773 | 2,446,755 | 95.31 | |
| ប្រៀបធៀបឆ្នាំមុន | | -90,684 | -506,709 | -152,778 | -3.17 | -353,931 | 3.17 | -19,459 | 64,805 | 18,377 | 23,143 | 1,767 | -11,552 | -6,044 | 72,119 | 6.40 | |

បានឃើញនិងឯកភាព
ត. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
**នាយកដ្ឋានផែនការនិងស្ថិតិ**

## ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៦

(គិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 1,340 | 1,000 | 1,967 | 1,759 | 70,015 | 84,919 | 170 | 30 | 970 | 1,120 | 155 | 172 | 72,650 | 88,208 | 121.42 |
| 02 | បាត់ដំបង | 48,600 | 48,100 | 56,270 | 54,597 | 138,200 | 128,508 | 110 | 103 | 1,430 | 903 | 16,760 | 5,402 | 205,100 | 191,186 | 93.22 |
| 03 | កំពង់ចាម | 5,180 | 3,090 | 6,815 | 4,417 | 12,330 | 23,072 | 380 | 243 | 3,990 | 6,097 | 6,640 | 6,188 | 28,520 | 42,415 | 148.72 |
| 04 | កំពង់ឆ្នាំង | 1,260 | 250 | 715 | - | 350 | 605 | 740 | 345 | 2,390 | 2,653 | 730 | 540 | 5,470 | 4,858 | 88.81 |
| 05 | កំពង់ស្ពឺ | 335 | - | 343 | - | 130 | 89 | 33 | 43 | 526 | 900 | 725 | 614 | 1,749 | 1,989 | 113.72 |
| 06 | កំពង់ធំ | 400 | - | 479 | - | 33,100 | 54,039 | 20 | 11 | 410 | 429 | 110 | 2,764 | 34,040 | 57,722 | 169.57 |
| 07 | កំពត | 2,660 | - | 1,282 | 498 | 1,610 | 739 | 780 | 347 | 2,930 | 1,495 | 2,570 | 761 | 10,550 | 4,624 | 43.83 |
| 08 | កណ្តាល | 12,460 | 11,640 | 9,029 | 3,995 | - | - | - | - | 4,204 | 3,185 | 203 | 75 | 16,867 | 12,289 | 72.86 |
| 09 | កោះកុង | 65 | - | 26 | - | 265 | 58 | 35 | 6 | 170 | 29 | - | 2 | 535 | 121 | 22.62 |
| 10 | ក្រចេះ | 1,300 | 930 | 3,427 | 2,986 | 5,000 | 66,066 | 50 | 94 | 450 | 510 | 99 | 747 | 6,899 | 70,844 | 1,026.87 |
| 11 | មណ្ឌលគិរី | 810 | 600 | 219 | 91 | 10,610 | 11,275 | 100 | 20 | 590 | 396 | 4,280 | 3,450 | 16,390 | 15,360 | 93.72 |
| 12 | ភ្នំពេញ | 128 | - | 116 | | 24 | 5 | 2 | 5 | 400 | 206 | 20 | 7 | 574 | 339 | 59.06 |
| 13 | ព្រះវិហារ | 10,061 | 4,281 | 12,511 | 2,519 | 17,749 | 20,102 | 460 | 535 | 735 | 622 | 9,352 | 7,879 | 38,357 | 41,649 | 108.58 |
| 14 | ព្រៃវែង | 2,380 | 2,380 | 1,698 | 1,639 | 500 | 947 | 10 | - | 940 | 533 | 1,510 | 800 | 5,340 | 3,978 | 74.49 |
| 15 | ពោធិ៍សាត់ | 1,970 | 1,750 | 4,158 | 3,902 | 10,000 | 22,922 | 215 | 24 | 500 | 396 | 1,470 | 1,184 | 14,155 | 28,684 | 202.64 |
| 16 | រតនគិរី | 160 | - | 718 | 625 | 13,400 | 17,261 | 40 | 16 | 70 | 49 | 510 | 380 | 14,180 | 18,424 | 129.93 |
| 17 | សៀមរាប | 900 | - | 405 | - | 7,335 | 17,985 | 310 | 215 | 1,840 | 1,475 | 1,575 | 3,188 | 11,960 | 23,268 | 194.55 |
| 18 | ព្រះសីហនុ | 25 | - | - | - | 110 | 40 | 10 | - | 275 | 125 | - | - | 420 | 165 | 39.29 |
| 19 | ស្ទឹងត្រែង | 1,340 | - | 665 | - | 14,000 | 13,428 | - | 100 | 550 | 467 | 1,000 | 1,012 | 16,890 | 15,672 | 92.79 |
| 20 | ស្វាយរៀង | 50 | - | 8 | - | 10,980 | 7,911 | 520 | 113 | 1,870 | 2,039 | - | - | 13,420 | 10,071 | 75.04 |
| 21 | តាកែវ | 393 | - | 109 | - | 642 | 1,698 | 117 | 397 | 1,078 | 842 | 232 | 169 | 2,462 | 3,215 | 130.58 |
| 22 | ឧត្តរមានជ័យ | 111 | - | 86 | - | 35,643 | 60,130 | 23 | 7 | 125 | 108 | 99 | 75 | 36,001 | 60,406 | 167.79 |
| 23 | កែប | 150 | 60 | 185 | 37 | 200 | 5 | 100 | 122 | 100 | 282 | - | - | 550 | 594 | 108.00 |
| 24 | ប៉ៃលិន | 4,015 | 4,000 | 2,178 | 2,168 | 5,000 | 59,087 | - | - | 15 | 18 | 1,000 | 26 | 10,030 | 61,309 | 611.26 |
| 25 | ត្បូងឃ្មុំ | 4,548 | 3,431 | 3,845 | 2,675 | 46,733 | 53,620 | 36 | 40 | 1,295 | 1,720 | 402 | 735 | 53,014 | 59,960 | 113.10 |
| សរុប | | **100,641** | **81,512** | **107,254** | **81,908** | **433,926** | **644,511** | **4,261** | **2,816** | **27,853** | **26,599** | **49,442** | **36,170** | **616,123** | **817,350** | **132.66** |
| តួលេខសប្តាហ៍មុន | | **100,641** | **81,512** | **107,165** | **81,907** | **433,926** | **644,504** | **4,261** | **2,810** | **27,853** | **26,502** | **49,442** | **36,169** | **616,123** | **817,150** | **132.63** |
| តួលេខឆ្នាំមុន | | **115,788** | **95,607** | **82,778** | **62,235** | **367,673** | **583,245** | **3,974** | **3,304** | **26,482** | **25,964** | **45,633** | **38,866** | **559,550** | **734,157** | **131.20** |
| ប្រៀបធៀបឆ្នាំមុន | | **-15,147** | **-14,095** | **24,476** | **19,673** | **66,253** | **61,266** | **287** | **-489** | **1,371** | **635** | **3,809** | **-2,696** | **56,573** | **83,193** | **1.46** |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | 70 | 14 | 350 | 38 | 145 | 156 | 165 | 235 | 55 | 40 | - | - | 785 | 483 | 61.53 |
| 02 | បាត់ដំបង | 600 | 163 | 20,600 | 1,585 | 12,850 | 428 | 160 | 161 | - | - | - | - | 34,210 | 2,337 | 6.83 |
| 03 | កំពង់ចាម | 2,810 | 733 | 16,340 | 8,251 | 11,140 | 7,584 | 570 | 911 | 10 | - | - | - | 30,870 | 17,479 | 56.62 |
| 04 | កំពង់ឆ្នាំង | 550 | 243 | - | - | 500 | 226 | 170 | 532 | 100 | 104 | 60 | 4 | 1,380 | 1,109 | 80.36 |
| 05 | កំពង់ស្ពឺ | 225 | 244 | - | - | 25 | 26 | 485 | 374 | - | - | - | - | 735 | 644 | 87.62 |
| 06 | កំពង់ធំ | 105 | 107 | 3,320 | 1,682 | 335 | 77 | 16 | 91 | - | - | - | - | 3,776 | 1,957 | 51.83 |
| 07 | កំពត | 735 | 188 | - | - | 100 | 1 | 1,040 | 818 | - | | - | | 1,875 | 1,007 | 53.71 |
| 08 | កណ្តាល | 52 | - | - | - | 1,232 | 72 | 800 | 571 | 25 | - | - | - | 2,109 | 643 | 30.49 |
| 09 | កោះកុង | 30 | 4 | - | 1 | - | - | 835 | 145 | - | - | - | | 865 | 150 | 17.34 |
| 10 | ក្រចេះ | 95 | 259 | - | 1,094 | 1,530 | 1,773 | 35 | 149 | - | - | - | - | 1,660 | 3,275 | 197.29 |
| 11 | មណ្ឌលគិរី | 3,500 | 3,941 | 2,500 | 1,963 | 35 | - | 140 | 41 | - | - | - | | 6,175 | 5,945 | 96.28 |
| 12 | ភ្នំពេញ | - | | - | | 7 | 19 | 6 | 12 | | | | | 13 | 31 | 238.46 |
| 13 | ព្រះវិហារ | 2,778 | 2,885 | 14,757 | 12,903 | 372 | 1,284 | 1,549 | 2,329 | - | - | 8 | 7 | 19,464 | 19,408 | 99.71 |
| 14 | ព្រៃវែង | - | 9 | - | - | 1,180 | 391 | 200 | 458 | - | - | - | - | 1,380 | 858 | 62.17 |
| 15 | ពោធិ៍សាត់ | 170 | 1,065 | 900 | 1,731 | 845 | 1,111 | 320 | 960 | - | - | - | - | 2,235 | 4,867 | 217.76 |
| 16 | រតនគិរី | 300 | 251 | 4,060 | 4,847 | 100 | 38 | 85 | 35 | | | 8 | 4 | 4,553 | 5,175 | 113.66 |
| 17 | សៀមរាប | - | 3 | 70 | 387 | 285 | 105 | 520 | 392 | - | - | - | - | 875 | 887 | 101.37 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | 30 | 35 | - | - | - | - | 30 | 35 | 116.67 |
| 19 | ស្ទឹងត្រែង | 1,000 | 576 | 2,200 | 1,897 | 500 | 300 | 500 | 275 | - | - | - | - | 4,200 | 3,048 | 72.57 |
| 20 | ស្វាយរៀង | 65 | - | - | - | - | - | 7,470 | 7,743 | - | - | - | - | 7,535 | 7,743 | 102.76 |
| 21 | តាកែវ | 100 | 71 | - | - | 19 | 33 | 311 | 220 | - | - | - | | 430 | 324 | 75.35 |
| 22 | ឧត្តរមានជ័យ | 75 | 65 | 6,180 | 2,505 | 55 | 40 | 44 | 33 | - | - | - | - | 6,354 | 2,643 | 41.60 |
| 23 | កែប | 30 | 25 | - | - | - | - | 70 | 121 | - | - | - | - | 100 | 146 | 146.00 |
| 24 | ប៉ៃលិន | 100 | 3 | 500 | 5 | 100 | - | 10 | 10 | - | - | - | - | 710 | 18 | 2.54 |
| 25 | ត្បូងឃ្មុំ | 930 | 1,010 | 1,370 | 755 | 2,045 | 600 | 574 | 515 | - | - | - | - | 4,919 | 2,880 | 58.55 |
| **សរុប** | | **14,320** | **11,859** | **73,147** | **39,644** | **33,400** | **14,264** | **16,105** | **17,166** | **190** | **144** | **76** | **15** | **137,238** | **83,092** | **60.55** |
| **តួលេខសប្តាហ៍មុន** | | **14,320** | **11,858** | **73,147** | **38,597** | **33,400** | **14,264** | **16,105** | **17,136** | **190** | **144** | **76** | **15** | **137,238** | **82,014** | **59.76** |
| **តួលេខឆ្នាំមុន** | | **13,754** | **13,351** | **71,332** | **57,925** | **29,070** | **24,203** | **15,335** | **15,643** | **190** | **100** | **61** | **67** | **129,742** | **111,289** | **85.78** |
| **ប្រៀបធៀបឆ្នាំមុន** | | **566** | **-1,492** | **1,815** | **-18,281** | **4,330** | **-9,939** | **770** | **1,523** | **0** | **44** | **15** | **-52** | **7,496** | **-28,197** | **-25.23** |

បានឃើញនិងឯកភាព

ភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៦

ន.- ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ប្រធានការិយាល័យស្ថិតិ